**Declassified to Public**
**12 April 2013**

D354

# ក្រុមមេធាវីការពារក្តី អៀង សារី
# IENG SARY DEFENCE TEAM
# EQUIPE DE DEFENSE DE IENG SARY

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 15 / 02 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Uch Arun

...មេធាវី អាង ឧត្តម និងមេធាវី Michael G. KARNAVAS
សហមេធាវីរបស់ អៀង សារី

ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១០

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / 02 / 2010
ម៉ោង (Time/Heure): 13:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ជូនចំពោះ៖ **ចៅក្រម យូ ប៊ុនឡេង**
**ចៅក្រម** Marcel LEMONDE
**សហចៅក្រមស៊ើបអង្កេត**

សំណើ៖ **សំណើសុំពិនិត្យមើលសំណុំរឿងទាំងមូល រួមទាំងឯកសារទាំងអស់ដែលលោកមាន ប៉ុន្តែគូភាគីពុំទាន់បានទទួល និងប្រព័ន្ធគ្រប់គ្រងសំណុំរឿង (casemap) បើសិនជាបានរៀបចំធ្វើ**

**សាធារណៈ** ~~សាធារណៈ~~ សម្ងាត់ CONFIDENTIAL CONFIDENTIEL 13/04/2010

លោកសហចៅក្រមជាទីគោរព៖

វិធាន៥៥(១១) នៃវិធានផ្ទៃក្នុងអនុញ្ញាតឲ្យភាគីមាន "សិទ្ធិសុំមើលសំណុំរឿងច្បាប់ដើម"[1]។ ដូច្នេះ ក្នុងនាមយើងខ្ញុំជាសហមេធាវីការពារក្តី (មេធាវីការពារក្តី) របស់លោក អៀង សារី យើងខ្ញុំស្នើសុំពិនិត្យឯកសារមួយចំនួនខាងក្រោមនេះ៖

(i) សំណុំរឿងទាំងមូល រួមទាំងឯកសារទាំងអស់ដែលលោកមាន ប៉ុន្តែគូភាគីពុំទាន់បានទទួល។

(ii) ប្រព័ន្ធគ្រប់គ្រងសំណុំរឿង casemap របស់ ក.ស.ច.ស ប្រសិនបើមាន ដែលជាប់ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ រួមទាំង អនុស្សរណៈផ្ទៃក្នុង កំណត់សំគាល់ទាក់ទិននឹង

---

[1] វិធាន ៥៥(១១) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

00454220

D354

កិច្ចស៊ើបសួរ ការវិភាគ និងលទ្ធផលការងាររបស់ ក.ស.ច.ស ទាក់ទិននឹងកិច្ចស៊ើបសួរក្នុងសំណុំរឿង០០២។

## ១. ការពិនិត្យមើលសំណុំរឿងទាំងមូល

ការពិនិត្យសំណុំរឿងទាំងមូល រួមទាំងឯកសារទាំងអស់ដែលលោកចៅក្រមមាន ប៉ុន្តែគូភាគីពុំទាន់បានទទួល មានភាពចាំបាច់ និងជាប់ពាក់ព័ន្ធនឹងមេធាវីការពារក្តី ដើម្បីធ្វើអោយប្រាកដថា តើកិច្ចស៊ើបសួរបន្ថែម គួរត្រូវធ្វើឡើង ហើយធ្វើត្រឹមកម្រិតណា ដើម្បីធានាឲ្យបាននូវកិច្ចស៊ើបសួរមួយដែលសមស្រប និងល្អិតល្អន់។ ម្យ៉ាងទៀតក្រៅពីរឿងដែលថាមេធាវីមានសិទ្ធិទទួលបានព័ត៌មានទាំងអស់ដែលបានស្នើសុំខាងលើ ក៏គួរបញ្ជាក់ផងដែរថាមេធាវីការពារក្តីបានបាត់បង់ទំនុកចិត្តទៅលើ ក.ស.ច.ស ដែលត្រូវធ្វើការស៊ើបសួរប្រកបដោយឯករាជ្យ និងអនាគតិ ។ កង្វះនូវទំនុកចិត្តមួយចំនួនទៅលើ កសចស នេះដោយសារហេតុផលដូចខាងក្រោម៖

- ភាពលម្អៀងរបស់អ្នកស៊ើបអង្កេត និងមន្ត្រីច្បាប់នៅក្នុង **កសចស**[2] ដែលបញ្ហានេះមិនត្រូវបានកាត់សេចក្តីទេ ដោយសារការប្រកាសមិនទទួលយកបញ្ហានេះមកកាត់សេចក្តី[3]។
- ភាពលម្អៀងរបស់សហចៅក្រម Lemonde ដែលត្រូវបានដឹងឮតាមរយៈអតីតប្រធានអង្គភាពព័ត៌មាន និងវិភាគនៃ **កសចស** គឺលោក Wayne Bastin[4]។

---

[2] *រឿងក្តី អៀង សារី សំណុំរឿងលេខ* ០០២/០៨-០៧-២០០៩-អ.វ.ត.ក-អ.ប.ជ, សំណើរបស់លោក អៀង សារី សម្រាប់ការប្តឹងជំទាស់ចិត្តសហចៅក្រមស៊ើបអង្កេតលោក Stephen Heder និង មន្ត្រីផ្នែកច្បាប់ ក.ស.ច.ស លោក David Boyle ក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត, ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៩, ឯកសារលេខ ១, ERN: 00348412-00348440។

[3] *រឿងក្តី អៀង សារី សំណុំរឿងលេខ* ០០២/០៨-០៧-២០០៩-អ.វ.ត.ក-អ.ប.ជ, សេចក្តីសម្រេចសំណើរបស់ជនត្រូវចោទ សម្រាប់ការប្តឹងជំទាស់ចិត្តលោកបណ្ឌិត Stephen Heder និងលោក David Boyle, ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩, ឯកសារលេខ ៣, ERN: 00378097-00378103។

[4] *រឿងក្តី អៀង សារី សំណុំរឿងលេខ* ០០២/០៩-១០-២០០៩-អ.វ.ត.ក-អ.ប.ជ, (០១), សំណើរបស់លោក អៀង សារី សុំប្តឹងជំទាស់ចិត្តសហចៅក្រមស៊ើបអង្កេត Lemonde និង សំណើសុំឲ្យមានសវនាការជាសាធារណៈ, ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩, ឯកសារលេខ ១, ERN: 00386956-00386968។ *រឿងក្តី អៀង សារី សំណុំរឿងលេខ* ០០២/១១-១២-២០០៩-អ.វ.ត.ក-អ.ប.ជ០៧, បណ្តឹងតាមវិធានផ្ទៃក្នុង ៣៤ លើកទី២ របស់លោក អៀង សារី សុំប្តឹងជំទាស់ចិត្តចៅក្រម Marcel LEMONDE និង ការសុំចូលរួមក្នុងបណ្តឹងរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ សុំប្តឹងជំទាស់ចិត្តសហចៅក្រមស៊ើប

00454221

D354

- កង្វះការសហការរបស់សហចៅក្រម Lemonde ជាមួយសហចៅក្រម យូ ប៊ុនឡេង ដែល ជាការរំលោភបំពានលើកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត **អវតក**[5]។
- ការរំលោភបំពានលើគោលការណ៍រក្សាការសម្ងាត់ក្នុងការស៊ើបអង្កេតរបស់លោកសហចៅក្រម Lemonde[6]។
- ការគំរាមរបស់លោកសហចៅក្រម Lemonde ទៅលើសុវត្ថិភាពរបស់សាក្សី[7]។
- ការទទូចរបស់ **កសចស** ក្នុងការទទួលយកភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម[8]។
- ការបដិសេធមិនពន្យល់អំពីវិធីសាស្ត្រស៊ើបអង្កេតជាក់លាក់របស់ **កសចស** ដោយរួមទាំងការប្រមូល និងវិភាគភស្តុតាងដោះបន្ទុកណាមួយ[9]។
- ការខកខានមិនបានបង្ហាញពីតម្លាភាពជុំវិញលក្ខណៈសម្បត្តិ និងបទពិសោធន៍របស់អ្នកស៊ើបអង្កេតរបស់សហចៅក្រម[10]។
- ការឱ្យយោបល់ជាចំហររបស់ **កសចស** ក្នុងការអនុវត្តតាមគោលការណ៍ "គ្រប់គ្រាន់នៃភស្តុតាង"[11]។

---

អង្កេត Marcel Lemonde និង សំណើសុំឱ្យមានសវនាការជាសាធារណៈ, ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩, ឯកសារលេខ ១, ERN: 00414160-00414179។

[5] *រឿងក្តី អៀង សារី សំណុំរឿងលេខ* ០០២/០៧-១២-២០០៩-អ.វ.ត.ក-អ.ប.ជ, (០៦), បណ្តឹងតាមវិធានផ្ទៃក្នុង ៣៥ របស់លោក អៀង សារី សុំប្តឹងផិតចិត្តចៅក្រម Marcel Lemonde, ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩, ឯកសារលេខ១, ERN: 00411800-00411815។

[6] *ដូចជើងទំព័រខាងលើ។*

[7] *ដូចជើងទំព័រខាងលើ។*

[8] *រឿងក្តី អៀងធីរិទ្ធ. សំណុំរឿងលេខ* ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស, ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាង ដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម, ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩, ឯកសារ D130/8, ERN: 00355926-00355933។

[9] *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស-D171, D130/7 & D130/7/2, ការិយាល័យសហចៅក្រមស៊ើបអង្កេត, "សំណើរបស់លោក សុំឱ្យបំពេញកិច្ចស៊ើបសួរ", ក្នុងចំណោមរឿងផ្សេងទៀតទាក់ទងនឹង យុទ្ធសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងកិច្ចស៊ើបសួរ ("ការឆ្លើយតប"), ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩, ឯកសារ D171/5, ERN: 00414038-00414049។

[10] *ដូចជើងទំព័រខាងលើ។*

[11] *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស, ដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម, ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩, ឯកសារ D164/2, ERN: 00355530-00355539, កថាខណ្ឌ៦។

- ការលើកឡើងរបស់ **កសចស** ដែលថាការបំពេញមុខងារដោយអនាគតិរបស់សហចៅក្រមស៊ើបអង្កេត មិនមែនជាកាតព្វកិច្ចក្នុងការស្វែងរកភស្តុតាងដោះបន្ទុកទេ[12]។
- ការដោះស្រាយរបស់ **កសចស** ចំពោះសំណើបំពេញកិច្ចស៊ើបសួរ មិនត្រូវបានអនុវត្តឱ្យអស់ពីសមត្ថភាពឡើយ។ ជាអាទិ៍ ការទាមទាររបស់ **កសចស** ឱ្យនរោត្តម សីហនុ បង្ហាញខ្លួននៅ **អវតក** ជាជាងសំណើស្តាប់សក្ខីកម្មរបស់ទ្រង់ពីព្រះបរមរាជវាំង ហាក់ដូចជាការធ្វើ ឡើងដោយចេតនា ដើម្បីធានាឱ្យមានលទ្ធផលអវិជ្ជមាន។
- ការប្រាស្រ័យទាក់ទងគ្នាជាមួយភាគីតែម្ខាង(*ex parte*)របស់ **កសចស** ជាមួយ **កសព**[13]។
- អសមត្ថភាពរបស់ **កសចស** ក្នុងការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃកំណត់ហេតុសម្ភាសន៍ជាលាយលក្ខណ៍អក្សរ[14]។
- ការប្រើប្រាស់អ្នកបញ្ចូលទិន្នន័យ/អ្នកវិភាគ ដែលគ្មានសមត្ថភាពខាងបកប្រែភាសា ឬខាងច្បាប់ ឱ្យសង្ខេបកំណត់ហេតុសម្ភាសន៍ជាលាយលក្ខណ៍អក្សរ[15]។
- កង្វះសមត្ថភាព និងអនាគតិរបស់អ្នកជំនាញខាងប្រជាសាស្ត្រដែលត្រូវបានតែងតាំងឱ្យធ្វើការ[16]។ បញ្ហាមួយនេះត្រូវបាន **កសចស**[17] ច្រានចោល។

ក.ស.ច.ស ត្រូវបានបង្កើតឡើងដើម្បីបំពេញមុខងារជាស្ថាប័នអនាគតិមួយ ដោយស៊ើបអង្កេតឥតលំអៀង ចំពោះអង្គហេតុទាំងឡាយដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[18]។

---

[12] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ១៥។

[13] *រឿងក្តី អៀង សារី* សំណុំរឿងលេខ002/១១-១២-២០០៩-អ.វ.ត.ក-អ.ប.ជ, (អ.ប.ជ07), បណ្តឹងតាមវិធានផ្ទៃក្នុង ៣៤ លើកទី២ របស់លោក អៀង សារី សុំប្តឹងជំទាស់ចិត្តចៅក្រម Marcel LEMONDE និង ការសុំចូលរួមក្នុងបណ្តឹងរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ សុំប្តឹងជំទាស់ចិត្តសហចៅក្រមស៊ើបអង្កេត Marcel Lemonde និង សំណើសុំឱ្យមានសវនាការជាសាធារណៈ, ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩, ឯកសារលេខ ១, ERN: 00414160-00414179, កថាខណ្ឌ១។

[14] *ដូចជើងទំព័រខាងលើ*។

[15] *ដូចជើងទំព័រខាងលើ*។

[16] *រឿងក្តី អៀង សារី* សំណុំរឿងលេខ002/១៩-០៩-២០០៧-អ.វ.ត/ក.ស.ច.ស, សំណើរបស់លោក អៀង សារី សុំអ្នកប្រជាសាស្ត្របន្ថែម, ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩, ឯកសារលេខ D140/2, ERN: 00355530-00355539។

[17] *រឿងក្តី អៀង សារី* សំណុំរឿងលេខ002/១៩-០៩-២០០៧-អ.វ.ត/ក.ស.ច.ស, ដីកាសម្រេចលើសំណើសុំចាត់តាំងអ្នកជំនាញការផ្នែកប្រជាសាស្ត្របន្ថែម, ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩, ឯកសារ D140/3, ERN: 00364629-00364633។

[18] វិធាន ៥៥(២) នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

D354

ជាការពិត ក.ស.ច.ស គឺជាភ្នាក់ងាររបស់ភាគី ដោយអនុវត្តកិច្ចស៊ើបសួរជំនួសភាគីទាំងអស់។ ដូច្នេះ ជាការសមហេតុផលដែលថាលទ្ធផលការងារទាំងអស់របស់ ក.ស.ច.ស គឺជាកម្មសិទ្ធិរបស់ភាគី។

ក្នុងការបដិសេធទៅលើសំណើសុំពិនិត្យព័ត៌មានពាក់ព័ន្ធកាលពីពេលកន្លងមក[19] ក.ស.ច.ស បានលើកយកវិធាន៧០(ក) នៃវិធានរបស់តុលាការ ICTY ស្តីពីនីតិវិធី និងភស្តុតាង មកធ្វើជាសំអាង៖

> បើទោះជាមានបញ្ញត្តិនៃវិធាន៦៦ និង៦៧ ក្តី ក៏របាយការណ៍ អនុស្សរណៈ ឬ ឯកសារផ្ទៃក្នុងផ្សេងៗ ដែលភាគី ជំនួយការ ឬអ្នកតំណាងទាក់ទិននឹងកិច្ចស៊ើបសួរ ឬការរៀបចំសំណុំរឿង បានរៀបចំឡើង មិនមែនជាកម្មវត្ថុដែលត្រូវផ្សព្វផ្សាយ ឬជូនដំណឹង តាមវិធានទាំងនេះឡើយ[20]។

យ៉ាងណាក៏ដោយ អ.វ.ត.ក ប្រើប្រព័ន្ធជជីកសួរដេញដោលដោយចៅក្រម (inquisitorial system)។ ក្នុងនាមជាតុលាការកម្ពុជា អ.វ.ត.ក ពុំមាននីតិវិធីដូចគ្នាទៅនឹងតុលាការ ICTY ទេ។ តុលាការ ICTY ប្រើប្រព័ន្ធឱ្យគូក្តីតទល់គ្នា (adversarial system) ដោយអនុញ្ញាតឱ្យ ភាគី

---

[19] *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត/ក.ស.ច.ស, សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទី៣របស់លោក អៀង សារី ("3RD IR"), ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩, ឯកសារ D171, ERN: 00330819-00330834។ *រឿងក្តី នួន ជា,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សំណើលើកទី២៣របស់លោក នួន ជា ស្នើសុំបំពេញកិច្ចស៊ើបសួរ ("23RD IR"), ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០, ឯកសារ D338, ERN: 00438961-00438970។

[20] *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស-D171, D130/7 & D130/7/2, ការិយាល័យសហចៅក្រមស៊ើបអង្កេត, "សំណើរបស់លោកសុំឱ្យបំពេញកិច្ចស៊ើបសួរ", *ក្នុងចំណោមរឿងផ្សេងទៀត* ទាក់ទងនឹងយុទ្ធសាស្រ្តរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងកិច្ចស៊ើបសួរ ("ការឆ្លើយតប"), ឯកសារ D171/5, ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩, *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ២៣, ជើងទំព័រ១២ "ជាឧទាហរណ៍ សូមមើល៖ [វិធាន ៧០ នៃវិធានផ្ទៃក្នុង] និងអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ITCY, *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Blagojević និង Jokić, សេចក្តីសម្រេចលើញត្តិបន្ទាន់របស់ Vidoje Blagojević ដើម្បីឱ្យអយ្យការបង្ហាញកំណត់សម្គាល់របស់ខ្លួនដែលបានមកពីការពិភាក្សាលើចម្លើយរបស់រដ្ឋអាជ្ញា ជាមួយនឹងជនជាប់ចោទ Nikolic នឹងសំណើសុំបើកសវនាការជាសាធារណៈបន្ទាន់,* ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៣៖ "*វិធាន ៧០ (ក) មានគោលបំណងការពារកុំឱ្យមានការបង្ហាញកំណត់ហេតុការងារ ដោយសារជាផលប្រយោជន៍សាធារណៈ ដែលព័ត៌មានទាក់ទងនឹងការរៀបចំផ្ទៃក្នុងនៃរឿងក្តី រួមទាំងទ្រឹស្តីផ្នែកច្បាប់ យុទ្ធសាស្រ្ត និងការស៊ើបសួរ ត្រូវបានទទួលបុព្វសិទ្ធិ និងមិនត្រូវបង្ហើបប្រាប់ភាគីបដិបក្ខនោះទេ*"។

D354

ព្រះរាជអាជ្ញា និងមេធាវីការពារក្តីអាចអនុវត្តកិច្ចស៊ើបសួរខ្លួនឯងដោយឡែក។ គោលបំណងនៃវិធាន ៧០(ក) នៅឯតុលាការ ICTY គឺដើម្បីការពារភាពសម្ងាត់របស់ភាគីនីមួយៗ នៅពេលរៀបចំសំណុំរឿងរៀងៗខ្លួន។ ប៉ុន្តែនៅ អ.វ.ត.ក កិច្ចស៊ើបសួរត្រូវបានបំពេញដោយ ក.ស.ច.ស សម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ភាពសម្ងាត់គួរតែពុំមែនជាបញ្ហាចោទឡើយ។ អាស្រ័យហេតុនេះ វិធាន ៧០ (ក) របស់តុលាការ ICTY ពុំត្រឹមតែពុំអាចយកមកអនុវត្តបាននោះទេ ប៉ុន្តែថែមទាំងពុំមានភាពចាំបាច់សម្រាប់ អ.វ.ត.ក ឡើយ។

នាពេលកន្លងមក ក.ស.ច.ស បានយកពាក្យពេចន៍ពីអត្ថបទមិនផ្លូវការមួយ (*Traité de l'instruction criminelle,* Faustin Hélie, ជំពូក៤ 'Attributions générales du Juge d'instruction') មកធ្វើជាមូលដ្ឋានក្នុងការបំពេញកិច្ចស៊ើបសួរដែលគ្មានគម្លាភាព[21]។ ដោយសេចក្តីគោរព យើងខ្ញុំសូមអះអាងថា ឯកសារមួយនេះពុំមែនមូលដ្ឋានសំអាងគួរឱ្យជឿជាក់បានដែលអាចយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក បានឡើយ។ វិធាននីតិវិធី និងភស្តុតាងនៅ អ.វ.ត.ក ចេញមកពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឬវិធានផ្ទៃក្នុង[22]។ មាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាអនុញ្ញាតឱ្យមេធាវីការពារក្តីអាច "ពិនិត្យសំណុំរឿង[23]" បាន។ វិធាន៥៥(១១) នៃវិធានផ្ទៃក្នុងអនុញ្ញាតឱ្យមេធាវីការពារក្តីមាន "សិទ្ធិសុំមើលសំណុំរឿងច្បាប់ដើម[24]" បាន។ ហេតុដូច្នេះ ក.ស.ច.ស គួរអនុញ្ញាតឱ្យភាគីអាចពិនិត្យមើលសម្ភារៈតាមការស្នើសុំ។

## ២. ការបង្កើត និងទទួលបានការពិនិត្យមើលប្រព័ន្ធគ្រប់គ្រងសំណុំរឿង casemap និងលទ្ធផលការងារពាក់ព័ន្ធទាំងអស់

---

[21] "ច្បាប់នោះប្រគល់អំណាចចាំបាច់ឱ្យ [ចៅក្រមស៊ើបអង្កេត] (...) ដើម្បីធានានូវសេរីភាពនៃសកម្មភាពរបស់ពួកគេ និងផ្តល់លទ្ធភាពឱ្យពួកគេធ្វើកិច្ចការរបស់ខ្លួនបាន", ដូចដែលតារាងសំអាងផ្លូវច្បាប់ពន្យល់អំពីមូលហេតុដែលគោលការណ៍សម្រាប់អនុវត្ត និងការពិភាក្សាផ្ទៃក្នុងរបស់អ្នកមិនមែនជាផ្នែកនៃសំណុំរឿង និងពីមូលហេតុដែលកិច្ចការទាំងនោះមិនត្រូវបង្ហាញដល់ភាគីទាំងឡាយ។ *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ៥០, ជើងទំព័រ ២២ ‹សន្និសញ្ញាស្តីពីការស៊ើបអង្កេតបទឧក្រិដ្ឋកម្ម, Faustin Hélie, ជំពូក ៤, *ភារកិច្ចទូទៅរបស់ចៅក្រមស៊ើបអង្កេត,* ទំព័រ ១៥៨›។

[22] *រឿងក្តី នួន ជា,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ០៦), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធលើពាក្យសុំមោឃភាព, ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨, ឯកសារ D55/I/8, ERN: 00219322-00219333, កថាខណ្ឌ ១៤-១៥។

[23] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា៣១៩។

[24] វិធាន ៥៥ (១១) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

D354

ប្រសិនបើ ក.ស.ច.ស បានបង្កើតប្រព័ន្ធគ្រប់គ្រងសំណុំរឿង casemap យើងខ្ញុំសូមស្នើដោយក្ដីគោរពថា ក.ស.ច.ស ត្រូវលាតត្រដាងប្រគល់ជូនគូភាគីក្នុងវិធីមួយដែលមានលក្ខណៈឆាប់រហ័ស។ យើងខ្ញុំក៏សូមអះអាងបន្ថែមទៀតថា សមាសធាតុនៃប្រព័ន្ធគ្រប់គ្រងសំណុំរឿង casemap គឺរួមមានអនុស្សរណៈផ្ទៃក្នុង និងលទ្ធផលការងារផ្ទៃក្នុងទាំងអស់របស់ ក.ស.ច.ស ដែលត្រូវបានយកទៅប្រើប្រាស់ ឬរៀបចំដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងសំណុំរឿង casemap។

ការពិនិត្យប្រព័ន្ធគ្រប់គ្រងសំណុំរឿង casemap និងការងារផ្ទៃក្នុងពាក់ព័ន្ធផ្សេងទៀត គឺជាការចាំបាច់មួយសម្រាប់មេធាវីការពារក្ដីក្នុងការអនុវត្តសកម្មភាពនានា ដែលក្នុងចំណោមនោះ (*inter alia*) ដូចមានរៀបរាប់ខាងក្រោម គឺសំដៅគាំពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក អៀង សារី[25]៖

- ពិនិត្យមើលថាតើគួរស្នើឲ្យ ក.ស.ច.ស បំពេញកិច្ចស៊ើបសួរបន្ថែមទៀតដែរ ឬយ៉ាងណា?
- ពិនិត្យមើលថាតើកិច្ចស៊ើបសួរត្រូវបាន ក.ស.ច.ស បំពេញប្រកបដោយអនាគតិដែរឬទេ[26]?
- ពិនិត្យមើលវិសាលភាពនៃការពឹងផ្អែកទៅលើភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម[27]។
- ជាប្រយោជន៍ដល់ការសន្សំសំចៃថវិកាតុលាការ និងសមភាពនៃមធ្យោបាយនៃការតទល់ក្ដី (equality of arms)។ ប្រសិនបើមេធាវីការពារក្ដីបានដឹងអំពីសំណុំរឿងប្រឆាំងនឹងលោក អៀង សារី កាន់តែឆាប់ នោះកិច្ចដំណើរការនីតិវិធីនឹងកាន់តែមានភាពយុត្តិធម៌។

---

[25] វិធាន ២១ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

[26] វិធាន៥៥(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

[27] *រឿងក្ដី អៀង ធីរិទ្ធ សំណុំរឿងលេខ* ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស, ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកពីការធ្វើទារុណកម្ម, ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩, ឯកសារ D130/8, ERN: 00355926-00355933។

00454226

D354

នៅក្នុងរឿងក្តី *ឌុច* អង្គបុរេជំនុំជម្រះបានយល់ឃើញថា ក.ស.ច.ស ពុំបានបញ្ជាក់អំពីអង្គហេតុដែលជាភស្តុតាងឲ្យបានលម្អិតគ្រប់គ្រាន់នៅឡើយទេ[28]។ ការបង្កើត និងការពិនិត្យប្រព័ន្ធគ្រប់គ្រងសំណុំរឿង casemap និងអនុស្សរណៈផ្ទៃក្នុងពាក់ព័ន្ធ និងលទ្ធផលការងារក្នុងការិយាល័យអាចជួយបញ្ចៀសរាល់បញ្ហាដែលធ្លាប់មានកន្លងមកនៅក្នុងរឿងក្តី *ឌុច*។

បន្ថែមពីលើសំណើរបស់យើងខ្ញុំនេះ គួរបញ្ជាក់ថាគោលបំណងនៃភាពច្បាស់លាស់នៅក្នុងអង្គហេតុដែលជាភស្តុតាង ក៏ត្រូវបានអង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិលើកយកមកបញ្ជាក់ក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Katanga* ដែលក្នុងនោះអង្គជំនុំជម្រះបានបញ្ជាក់ថាមាន "គោលបំណងពីរនៅក្នុងការបង្ហាញភស្តុតាងដាក់បន្ទុក ដែលភាគីរដ្ឋអាជ្ញាចង់លើកយកមកសំអាងនៅក្នុងការជំនុំជម្រះនៅក្នុងទម្រង់ជាតារាង។ គោលបំណងទីមួយគឺថា តារាងនេះមានភាពចាំបាច់ក្នុងការធានាថា ពុំមានភាពស្រពេចស្រពិលណាមួយនៅក្នុងអង្គហេតុដែលត្រូវបានចោទប្រកាន់ដែលបញ្ជាក់អំពីបទចោទដែលអង្គបុរេជំនុំជម្រះបានបញ្ជាក់នោះ។ ទីពីរ តារាងនេះក៏ជាការចាំបាច់ដែរសម្រាប់បង្ហាញប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌នូវភស្តុតាងដែលភាគីរដ្ឋអាជ្ញាចង់លើកយកមកសំអាងក្នុងការជំនុំជម្រះក្តី[29]"។

តាមហេតុផលទាំងប៉ុន្មានដែលបានលើកឡើងខាងលើ យើងខ្ញុំសូមស្នើដោយក្តីគោរពសុំឱ្យលោកសហចៅក្រមឆ្លើយតបនឹងសំណើនេះអោយបានលឿន ដើម្បីជាប្រយោជន៍ដល់តម្លាភាព ការគាំពារសិទ្ធិរបស់លោក អៀង សារី និងភាពច្បាស់លាស់។

ជាការចាំបាច់ដែលសាធារណជនក៏ដូចជាមេធាវីការពារក្តី ត្រូវដឹងអំពីនីតិវិធីត្រឹមត្រូវក្នុងការជំនុំជម្រះបទឧក្រិដ្ឋ។ ដូច្នេះទើបបានជាយើងខ្ញុំចាត់ទុកឯកសារនេះថាជាឯកសារសាធារណៈ និងគួរជូនដំណឹងឱ្យសាធារណជនបានជ្រាបទៅតាមការគួរ។

---

[28] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច"*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០២), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ ២០០៨, ឯកសារ D99/3/42, ERN: 00249846-00249887, កថាខណ្ឌ ៥៦-៥៧។

[29] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Katanga និងអ្នកផ្សេងទៀត*, ICC-01/04-01/07-956, ដីកាស្តីអំពីការបង្ហាញភស្តុតាងដាក់បន្ទុក និងសេចក្តីណែនាំតុលាការតាមប្រព័ន្ធអ៊ីនធីណិត(E-Court)អង្គជំនុំជម្រះសាលាដំបូងII, ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩, កថាខណ្ឌ ៥។

D354

សូមលោកសហចៅក្រមទទួលនូវក្តីគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

មេធាវី **អាង ឧត្តម** មេធាវី **Michael G. KARNAVAS**

សហមេធាវីរបស់លោក អៀង សារី